**សេចក្តីព្រាង**
ពិគ្រោះយោបល់
ពីថ្ងៃពិគ្រោះយោបល់ដល់ថ្ងៃទី...
ខែ..... ឆ្នាំ២០១០

# អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

# ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
## ELECTRICITY LAW OF THE KINGDOM OF CAMBODIA

**សេចក្តីសម្រេចកែសម្រួលលើកទី ១**
**លើឯកសារអាជ្ញាប័ណ្ណ លេខ ២៦១ ឯអ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩**
**សម្រាប់សហគ្រាស អភិវឌ្ឍន៍អគ្គិសនីជនបទ ធ្វើសេវាកម្មអគ្គិសនីនៅឃុំស្នោ,**
**ឃុំឆក់ឈើនាង, ឃុំឪឡោក និងឃុំពន្សាំង ស្រុកអង្គស្នួល ខេត្តកណ្តាល**

**សម្រាប់ការប្តូរឈ្មោះម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ**

**DECISION ON THE FIRST REVISION**

**OF THE LICENSE DOCUMENT No. 261 LD DATED DECEMBER 25, 2009**

**FOR SAHAKREAS APHIVATH AKISNI CHUNABORT FOR PROVIDING POWER GENERATION**

**AND DISTRIBUTION SERVICES AT KHUM SNAO, KHUM CHAUK CHER NEANG, KHUM**

**OVLOAK AND KHUM PONGSAING, ANGSNOUL DISTRICT, KANDAL PROVINCE**

**FOR CHANGING THE NAME OF OWNERSHIP OF LICENSEE**

**ថ្ងៃទី ខែ ឆ្នាំ២០១០**

**, 2010**

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA
លេខ : -១០.អអក

# សេចក្តីសម្រេចកែសម្រួលលើកទី ១ លើឯកសារអាជ្ញាប័ណ្ណ លេខ ២៦១ ឯអ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ សម្រាប់សហគ្រាស អភិវឌ្ឍន៍អគ្គិសនីជនបទ

# DECISION ON THE FIRST REVISION

# OF THE LICENSE DOCUMENT No. 261 LD DATED DECEMBER 25, 2009 FOR SAHAKREAS APHIVATH AKISNI CHUNABORT

## អាជ្ញាធរអគ្គិសនីកម្ពុជា
## ELECTRICITY AUTHORITY OF CAMBODIA

- អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១
- In exercise of the powers conferred by Article 7 and 35 of the Electricity Law promulgated by the Royal Decree NS/RKM/0201/03, dated 02/02/2001.
- យោងឯកសារអាជ្ញាប័ណ្ណលេខ ២៦១ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យសហគ្រាស អភិវឌ្ឍន៍អគ្គិសនីជនបទ នៅថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩
- In accordance with License Documents No. 220 LD issued by Electricity Authority of Cambodia on June 06, 2008 to SAHAKREAS APHIVATH AKISNI CHUNABORT
- យោងពាក្យស្នើសុំប្តូរម្ចាស់កម្មសិទ្ធិរបស់សហគ្រាស អភិវឌ្ឍន៍អគ្គិសនីជនបទ ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១០
- In accordance with the application for changing the owner of SAHAKREAS APHIVATH AKISNI CHUNABORT, dated May 07, 2010.
- យោងលិខិតរបស់ក្រសួងពាណិជ្ជកម្ម លេខ ២០៤៧ ពណ.ចបព ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១០
- In accordance with the letter of Ministry of Commerce No. 2047, dated May 04, 2010.
- យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី ខែ ឆ្នាំ២០១០ ដល់ថ្ងៃទី ខែ ឆ្នាំ២០១០
- In accordance with the consultation with concerned parties and public, made from , 2010 to , 2010
- យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី នៅថ្ងៃទី ខែ ឆ្នាំ២០១០
- In accordance with the decision of Electricity Authority of Cambodia's Session No. dated , 2010.

# សម្រេច

# DECIDES

**ប្រការ១**

កែសម្រួលឯកសារអាជ្ញាប័ណ្ណ លេខ ២៦១ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជា ចេញឱ្យ**សហគ្រាស អភិវឌ្ឍន៍អគ្គិសនីជនបទ** ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៩ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅឃុំស្នោ ឃុំឆក់ឈើនាង ឃុំឱឡោក និងឃុំពន្សាំង ស្រុកអង្គស្នួល ខេត្តកណ្តាល ដោយប្តូរឈ្មោះម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណពី **លោក កេះ គុយ** ទៅជា **លោក ភូ ខៀវ** (បន្ទាប់ពីនេះហៅថា "**អ្នកកាន់អាជ្ញាប័ណ្ណ**") មានទីស្នាក់ការនៅផ្ទះលេខ ១៦ ផ្លូវលំ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដែលបានចុះបញ្ជីពាណិជ្ជកម្មលេខ Co.4007/09I ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៩ នៅក្រោមបទបញ្ញត្តិនៃក្រមពាណិជ្ជកម្ម និងរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ ២**

ឧបសម្ព័ន្ធទី៤ ដែលភ្ជាប់ជាមួយឯកសារអាជ្ញាប័ណ្ណលេខ ២៦១ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី៤ កែសម្រួលថ្មីដែលមានភ្ជាប់មកជាមួយ ។

**ប្រការ ៣**

សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ត្រូវក្លាយជាផ្នែកមួយនៃឯកសារអាជ្ញាប័ណ្ណលេខ ២៦១ឯអ ។

**ប្រការ ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ២៦១ ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦**

អ្នកកាន់អាជ្ញាប័ណ្ណត្រូវផ្ញើសេចក្តីសម្រេចនេះទៅតម្កល់ទុកបន្ថែម នៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណ លេខ ២៦១ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ២៦១ ឯអ ដែលតម្កល់មានការកែសម្រួលជាថ្មីស្រប តាមសេចក្តីសម្រេចនេះ ។

**Article 1**

To revise the license document No. 220 LD on June 06, 2008 which was issued to **Sahakreas Aphivath Akisni Chunabort** for providing electricity service at Khum Snao, Khum Chauk Cher Neang, Khum Ovloak and Khum Pongsaing, Angsnoul District, Kandal Province is now changing the name of ownership of licensee from **Mr. Kes Kuy** to **Mr. Phour Khiev** (herein after referred to as "Licensee") located at #16, Plovlom, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh City, registered in the Kingdom of Cambodia under Co.4007/09I dated March 13, 2009 pursuant to the Commercial and Civil Law.

**Article 2**

The existing schedule 4 of the license document No. 261 LD is replaced by the new revised schedule 4 attached here with.

**Article 3**

This decision and the attached Schedule are the part of license document No.261 LD.

**Article 4**

The other contents and conditions of the license document No.261 LD shall remain in force.

**Article 5**

The decision shall come into force from the date of signing.

**Article 6**

The licensee shall send this decision to deposit additionally at the places, where the license document No. 261 LD has been deposited in order that the deposited license document No. 261 LD is in conformity with this decision.

ភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០១០

Phnom Penh, , 2010

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

CHAIRMAN OF ELECTRICITY AUTHORITY OF CAMBODIA

# ឧបសម្ព័ន្ធទី៤
# ម្ចាស់កម្មសិទ្ធិនៃអ្នកកាន់អាជ្ញាប័ណ្ណ

**SCHEDULE 4**

**OWNERSHIP OF LICENSEE**

| | |
|---|---|
| ១- **សហគ្រាស អភិវឌ្ឍន៍អគ្គិសនីជនបទ** គឺជាសហគ្រាសឯកបុគ្គល ដែលមានលោក **ភួ ខៀវ** ជាឯកកម្មសិទ្ធិករ។ | 1- Mr. **Phour Khiev** is the single owner of **Sahakreas Aphivath Akisni Chunabort.** |
| ២- យោងតាមមាត្រា ៤៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ម្ចាស់កម្មសិទ្ធិដែលបានចុះបញ្ជីដូចខាងលើ ពុំអាចមានភាគហ៊ុន ឬមានផលប្រយោជន៍ហិរញ្ញវត្ថុផ្ទាល់ ជាមួយអ្នកកាន់អាជ្ញាប័ណ្ណផ្សេងទៀតដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍ពីអាជ្ញាធរអគ្គិសនីកម្ពុជាឡើយ ។ ក្នុងករណីជាក់លាក់ណាមួយដើម្បីជាផលប្រយោជន៍សាធារណៈ អាជ្ញាធរអគ្គិសនីកម្ពុជាអាចចេញសេចក្តីសម្រេចអនុញ្ញាតឱ្យបាន ។ | 2. Refer to Article 45 of the Electricity Law of the Kingdom of Cambodia, the above registered owners shall not own shares in or have any other direct financial interests in any other licensee without written permission from EAC. EAC may permit in specific cases in public interest. |